ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២១៩

ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥

សាលដីកា

លេខ : ៨៧

ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦ ដែលមានសមាសភាពដូចខាងក្រោម :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

២ - លោក សោម សិរីវឌ្ឍ ជាចៅក្រម

៣ - លោក ប៉ែន សារឿន ជាចៅក្រម

៤ - លោក យូរ ឧត្តរា ជាចៅក្រមរបាយការណ៍

៥ - លោក មុំង មុន្នីចរិយា ជាចៅក្រម

លោក ឡេង វុធ ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខៈ ៥៨ " គ " ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខៈ ១៦៣ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ រីម រ៉ង ( ជាម្ចាស់បណ្តឹងសាទុក្ខ ) ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅ ភូមិអូរ ឃុំផ្អាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ ម៉ូ រីម " ស " ម្តាយឈ្មោះ ពួញ ហួត " រ " ។ ជាតំណាងឱ្យប្រជាជនចំនួន ៨៤គ្រួសារ ។

មានមេធាវីលោក ណុស បូផល ។

និង ចុងចម្លើយឈ្មោះ សាលិញ ដឿម ( ចុងបណ្តឹងសាទុក្ខ )ភេទប្រុស ជាតិខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅ ភូមិស្វាយសរ ឃុំផ្អាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ ម៉ក់ សាលី " ស " ម្តាយឈ្មោះ យ៉ាន់ សឿន "ស " ។ តំណាងឱ្យប្រជាជនភូមិស្វាយសរ ។

មានមេធាវីលោក ស៊ិន សុវន ។

<u>**កម្មវត្ថុបណ្តឹង:**</u> ប្តឹងទាមទារដីស្រែទំហំ ១.៥០០ម x ៩០០ម ។

បានឃើញបណ្តឹងសាទុក្ខលេខ: ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ រីម រ៉ង បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ: ២១៩ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១០-០៥-២០០២ របស់ឈ្មោះ រឹម រ៉ង ជាតំណាងឱ្យប្រជាពលរដ្ឋចំនួន ៨៤គ្រួសារ ប្ដឹងសុំទាមទារដីស្រែទំហំ ១.៥០០ម x ៩០០ម ពីប្រជាជនភូមិស្វាយសរ ដោយសំអាងហេតុថា ប្រជាជន ភូមិអូរ របស់ខ្លួនបាននឹងកំពុងធ្វើស្រែលើដីនេះចាប់តាំងពីឆ្នាំ ១៩៩២ រហូតមកដល់បច្ចុប្បន្ននេះ និង មានលិខិតកាន់កាប់ដី ពីលោកមេឃុំថ្កាំនាឆ្នាំ ១៩៩២ និង លិខិតកាន់កាប់ដីមួយទៀតក្នុងឆ្នាំ ១៩៩៦។ ស្រាប់តែដល់ឆ្នាំ ២០០១-២០០២ នេះប្រជាជនភូមិស្វាយសរដែលដឹកនាំដោយលោក សា លិញដឿម បានបំផុសឱ្យប្រជាជនមក ភ្ជួរយកដីស្រែដែល ជាកម្មសិទ្ធិរបស់ប្រជាជនភូមិអូរ ដោយសំអាងហេតុថា ជាដីកេរ្ដិ៍តំណែលរបស់ខ្លួនតាំងពីសង្គមរាស្ត្រនិយមមកម្ល៉េះ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខៈ ៩២ " ក " ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្ត បន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ÷

១ - ទទួលពាក្យបណ្ដឹងចុះថ្ងៃទី០១-០៥-២០០២ របស់ដើមចោទឈ្មោះ រឹម រ៉ង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៤-០៦-២០០២ របស់ប្រជាជនភូមិអូរមកឱ្យឈ្មោះ រឹម រ៉ង ទុកជា ត្រឹមត្រូវតាមច្បាប់ ។

៣ - ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០១-០៧-២០០២ របស់ប្រធានភូមិស្វាយសរមកឱ្យឈ្មោះ សា លិញដឿម ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤ - ប្រគល់ដីទំនាស់ទំហំ ១.៥០០ម៉ែត្រ x ៩០០ម៉ែត្រស្ថិតនៅភូមិអូរ ឃុំថ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយ មានជ័យ ឱ្យប្រជាជនភូមិអូរចំនួន ៨៤គ្រួសារ ដែលមានឈ្មោះ រឹម រ៉ង ជាតំណាងកាន់កាប់បង្កបង្កើនផល និង ប្រើ ប្រាស់ជាកម្មសិទ្ធិកាលណាសាលក្រមចូលជាស្ថាពរ ។

៥ - កាត់យកប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០៛០០ ដែលដើមចោទបានបង់ទុករួចហើយ គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធហ្វឹង ១.៨០០៛០០, សោហ៊ុយកិច្ចការស៊ើបអង្កេត ៥.០០០៛០០ និង រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០។ កាលបើសាលក្រមនេះចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយ គឺ ប្រជាជនភូមិស្វាយសរចំនួន ១៤២គ្រួសារ ដែលមាន ឈ្មោះ សា លិញដឿម ជាតំណាងរួមគ្នាបង់ប្រាក់នេះទៅដើមចោទវិញ និង បង្គាប់ឱ្យចុងចម្លើយរួម គ្នាបង់ពន្ធ សមាមាត្រមួយភាគរយលើដីទំនាស់នេះដែលជាប្រយោជន៍ថវិការដ្ឋ ៨០% និង ជាប្រយោជន៍ដល់ក្រឡាបញ្ជីកាន់ ហិបប្រាក់ ២០%។

សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍លេខៈ ៥៥ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះ សា លិញដឿម បានប្ដឹងមិនសុខចិត្តនឹងសាលក្រមរបស់តុលាការខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញ សាលដីការបៀបលេខៈ ១២ "គ" ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ÷

១ - បង្គាប់ឱ្យអាជ្ញាធរជំនាញគូសប្លង់ពីទំហំដីព្រៃ និង ដីបង្កបង្កើនផលជាក់ស្តែងរបស់គូភាគីនីមួយៗដោយមានការចូលរួមរវាងភាគីទំនាស់ជាតំណាង ។

២ - រាយការណ៍ពីទំហំដីបង្កបង្កើនផលរបស់ភូមិនីមួយៗក្រៅពីដីទំនាស់ ។

៣- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី ។

បានឃើញសាលដីការដ្ឋប្បវេណីលេខៈ ៥៨ " គ " ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ÷

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សា លិញដឿម តំណាងឱ្យប្រជាជនភូមិស្វាយសរ ចុះថ្ងៃទី ០៦-០៨-២០០២ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - បដិសេធសាលក្រមរដ្ឋប្បវេណីលេខៈ ៥២ " ក " ចុះថ្ងៃទី១៩-០៧-២០០២ របស់តុលាការខេត្តបន្ទាយមានជ័យចោលជាអសារបង់ ។

៣ - ទទួលពាក្យបណ្តឹងចុះថ្ងៃទី០១-០៥-២០០២ របស់ដើមចោទឈ្មោះ រឹម រ៉ង តំណាងឱ្យប្រជាជនភូមិអូរ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៤ - ដីទំនាស់ដែលមានទំហំតាមគំនូសប្លង់ទីតាំងដីទំនាស់លេខៈ ១០៨/០៥ ជនសស.បជ/សដក ចុះថ្ងៃទី ០៥-០៥-២០០៥ ត្រូវបែងចែកជាពីរឱ្យភាគីម្ខាងៗកាន់កាប់តាមច្បាប់ តាមគំនូសគូសបន្ថែមដោយតុលាការមានចំណុច A និង ៦ ជាបន្ទាត់ពុះ គឺ :

- ទំហំ ABCDEFGAដែលដែលមានបន្ទាត់ BC =៥០០ម និង បន្ទាត់ GA=៥០០ម ។

ក/- ផ្នែកខាងកើតប្រគល់ឱ្យប្រជាជនភូមិអូរ ។

ខ/- ផ្នែកខាងលិចដីទំនាស់សល់ពីចំណុចខាងលើ ប្រគល់ឱ្យប្រជាជនភូមិស្វាយសរ ។ សំណូមពរលើសពីនេះបដិសេធចោល ។

៥ - កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛០០ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛០០ និង លើអាជ្ញាធរតុលាការ ៥.០០០៛០០ និង បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ ១% លើចំណែកដីទំនាស់ពាក់កណ្តាលដែលបានជាប្រយោជន៍ថវិការដ្ឋ ៨០% និង រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។

៦ - សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៩-០៦-២០០៥ និង ប្រកាសជាសាធារណៈនៅថ្ងៃទី១៥-០៦-២០០៥ ចំពោះមុខគូភាគី បើថ្វីប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខៈ ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ រឹម រ៉ង បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណារបស់ឈ្មោះ រឹម រ៉ង តំណាងឱ្យប្រជាជន ៨៤ គ្រួសារចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៥ ។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះ មូល ឃឿន. ទន់ ឈឿង តំណាងឱ្យប្រជាជន១៤២គ្រួសារចុះថ្ងៃទី

២២ ខែកក្កដា ឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខរបស់ឈ្មោះ រីម រ៉េង ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកជំនុំជំរះបាន ។

សាលដីការដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

អាស្រយ័ហេតុនេះ សូមក្រុមប្រឹក្សា ជំនុំជំរះ មេត្តាពិនិត្យ និង សំរេចតាមច្បាប់ ។

លោក រីម រ៉េង បាឆ្លើយថា : ខ្លួនប្តឹងសាទុក្ខមកនេះ គឺ សុំឱ្យតុលាការកំពូល សំរេចសេចក្តីដូចសាលក្រមរបស់តុលាការខេត្តបន្ទាយមានជ័យវិញ ដីទំនាស់នេះសព្វថ្ងៃកំពុងបង្កបង្កើនផលពាក់កណ្តាលម្នាក់ ។

មេភូមិអូរ បានឆ្លើយថា : ដីទំនាស់នេះគឺជាដីរបស់ប្រជាជនភូមិរបស់ខ្លួនទេ ហើយប្រជាជនស្វាយសរមករំលោភយកដីរបស់ប្រជាជនភូមិខ្លួនប្រាកដមែន ។

សំណូមពរសុំឱ្យតុលាការកំពូលជួយសំរួលដីនេះជូនប្រជាជនខ្លួនផង ។

លោក មូល ឃឿន បានឆ្លើយថា : ពាក្យដែលគាត់បានលើកឡើងថាចូលមកកាន់កាប់តាំពីឆ្នាំ៩២ មកនោះមិនត្រឹមត្រូវទេព្រោះដីនេះជាតំបន់អសន្តិសុខគ្មានអ្នកណាមកកាន់កាប់មុនឬក្រោយទេគឺចូលមកកាន់កាប់តំណាលគ្នា

សំណូមពរ : សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

លោក ទន់ ឈឿង បានឆ្លើយថា : សុំឱ្យតុលាការបញ្ចប់រឿងក្តីនេះត្រឹមនេះដោយតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការវិញ ។

មេធាវីលោក ណូស បូផល ការពារឱ្យប្រជាជនភូមិ អូរ បានធ្វើធ្វើសេចក្តីសន្និដ្ឋានថា :

ខ្លួនសុំលើកពីអង្គហេតុត្រួស១ដើម្បីជូនជ្រាបជាមុន ដីនេះមុនជាតំបន់អស្តិសុខហើយជាកន្លែងដែលសមរភូមិក្តៅមិនដែលមានប្រជាជនណាមកបង្កបង្កើនផលលើដីនេះឡើយ ទើបនៅពេលបញ្ចប់សង្គ្រាមរដ្ឋអំណាចប្រជាជនភូមិអូរបង្កបង្កើនផលលើដីនេះ ស្រាប់តែនៅឆ្នាំ២០០១-២០០២ មានប្រជាជនភូមិស្វាយសរចូលមករំលោភកាន់កាប់ដីនេះដែលជាដីរបស់ភូមិអូរ ។ ដីទំនាស់នេះប្រជាជនភូមិអូរបានកាប់ឆ្ការស្អាតបាតហើយ ទើបប្រជាជនភូមិស្វាយសរមកបំពានយកតែម្តង នៅតុលាការខេត្តបន្ទាយមានជ័យបានសំរេចប្រគល់ឱ្យប្រជាជនភូមិអូរជាកម្មសិទ្ធិតាមច្បាប់ហើយ ។ សាលាឧទ្ធរណ៍បានសំរេចចែកដីនេះជាពីរដែលមិនបានយកច្បាប់អ្វីមកធ្វើជាសំអាងឡើយ គឺ យកប្លង់ដីមកពុះបំបែកជាពីរតែម្តង ដែលមានលក្ខណៈខុសពីភាពជាក់ស្តែងនៃប្លង់ដីនេះស្រឡាស់ ។

តាមច្បាប់ការកាន់កាប់របស់ប្រជាជនភូមិអូរ គឺមានលក្ខណៈពិសេសព្រោះ គាត់មានលទ្ធកម្មពិសេស ដែលបញ្ជាក់ថា ដីនេះជារបស់ប្រជាជនភូមិអូរប្រាកដណាស់ ។ ចំណែកឯប្រជាជនភូមិស្វាយសរទើបចូលមកធ្វើការបង្កបង្កើនផលនៅពេលក្រោយដែល តុលាការកំពូល បានចេញលិខិតឱ្យហាមឃាត់. ដូច្នេះប្រជាជនភូមិស្វាយសរ បានបំពានលើច្បាប់ទាំងស្រុង ។

សមណ្ហមពរ : សុំបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

មេធាវីអ្នកស្រី ស៊ិន សុវ៉ែន ការពារឱ្យប្រជាជនភូមិស្វាយសរ បានធ្វើសេចក្ដីសន្និដ្ឋានថា :

តាមការដែលខ្លួនបានចុះទៅស៊ើបសួរ និង អង្កេតដល់ទីកន្លែងផ្ទាល់ឃើញថា នៅឆ្នាំ ១៩៧៩-១៩៩២ ដីនេះមិនមានអ្នកណាចូលមកបង្កបង្កើនផលលើដីនេះឡើយ ព្រោះតំបន់នោះជាតំបន់អសន្តិសុខមិនមានជនណាចូលមកបង្កបង្កើនផលបានឡើយ ។

ទើបតែមានសន្តិសុខបានប្រជាជននាំគ្នាចុះបង្កបង្កើនផលលើដីនេះតំណាលគ្នា គឺមិនអាចមានអ្នកណាធ្វើមុនធ្វើក្រោយឡើយ ហើយជាក់ស្ដែងសព្វថ្ងៃប្រជាជនទាំងពីរភូមិនេះកំពុងតែបង្កបង្កើនផលលើដីនេះពាក់កណ្ដាលម្នាក់ តែភូមិអូរបានដីធំជាងភូមិស្វាយសរ ។ នៅពេលដែលប្រជាជនភូមិស្វាយសរភ្ជួរដីសាបព្រោះស្រូវហើយ ប្រជាជនភូមិអូរបានមកភ្ជួររាស់ពីលើបណ្ដាលឱ្យខូចខាតផលដំណាំអស់ ឯកឧត្តម កាលពីមុនប្រជាជនភូមិអូរ និង ភូមិស្វាយសរជាភូមិតែមួយទេ ដោយមានកំណើនប្រជាជនច្រើនទើបគេបំបែកជាពីរភូមិ ដូច្នេះបានជាដីនេះត្រូវបែកជាពីរតាមរបបប្រជាជន ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអាយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយរបស់គូភាគី និង សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា : បណ្ដឹងសាទុក្ខលេខ: ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ រឹម រ៉េង ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមក ជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

យល់ឃើញថា : ពុំមានភស្ដុតាងដែលបញ្ជាក់ច្បាស់ថា ប្រជាជនភូមិអូរ បានចូលមកកាន់កាប់ជាក់ស្ដែងលើដីទំនាស់តាំងតែពីឆ្នាំ ១៩៩២ ក្រោយពីលោក រឿង ចំ បានប្រគល់ឱ្យតាមលិខិតចុះថ្ងៃទី០៩-០៩-១៩៩២ នោះឡើយ ដោយហេតុថាលោក រឿង ចំ បានបញ្ជាក់តាមលិខិតចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ ថា ថ្វីត្បិតតែលោកជាអ្នកអនុញ្ញាតឱ្យអ្នកភូមិអូរមែន តែលោកមិនបានដឹងពីការកាន់កាប់ជាក់ស្ដែងនោះទេ និង ម្យ៉ាងទៀតទាំងលោក រឿង ចំ ក្ដី លោក អាង កេទ ជាមេភូមិថ្មីក្នុងឆ្នាំ២០០១ ក្ដី ក៏ដូចជាលោក ជេង ប៉ោត ដែលជាមេភូមិថ្មីក្រោយដែរ បានបញ្ជាក់ក្នុងន័យប្រហាក់ប្រហែលគ្នាថា ប្រជាជនទាំងពីរភូមិចាប់ផ្ដើមចូលកាន់កាប់ដីទំនាស់នេះនៅឆ្នាំ ២០០១ ដូចគ្នាទើបកើតមានទំនាស់ ដូចនេះការដែលសាលាឧទ្ធរណ៍លើកយកគោលការណ៍សមធម៌មកពិចារណា និង សំរេចនោះជាការត្រឹមត្រូវហើយ ។

យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ: ៥៨ "គ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១ - ទទួលបណ្តឹងសាទុក្ខលេខ: ២៣១ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ រឹម រ៉ង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខ: ៥៨ "គ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលដើមចោទបានបង់ គឺ÷

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សំរាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.
- ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

បង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤ - សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦ ។